ប្រជាកាសែត-Prochea Kaset

14h ·

ប្រជាសហគមន៍បឹងត្របែកប្រមាណ២០នាក់ជួបជុំនៅខណ្ឌចំការមនទាមទារដំណោះស្រាយដីធ្លី

(អត្ថបទដោយ៖ ហុង សេរីហួង)

ប្រជាសហគមន៍បឹងត្របែករស់នៅអមប្រឡាយលូ ក្នុងសង្កាត់ផ្សារដើមថ្កូវ២១នាក់តំណាងឱ្យពលរដ្ឋ២១គ្រួសារ បានទៅជួបជុំគ្នានៅមុខរដ្ឋបាលខណ្ឌចំការមន នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦ ដើម្បីស្នើសុំអភិបាលខណ្ឌជួយដោះស្រាយបញ្ហាដីធ្លី ។

ប្រជាសហគមន៍បឹងត្របែកភូមិ៥ លោក លី រ៉ាវី ប្រាប់ប្រជាកាសែតថា ប្រជាពលរដ្ឋចំនួន២១នាក់ រួមទាំងលោកផង ដែលតំណាងឱ្យពលរដ្ឋ ២១គ្រួសារបានទៅជួបជុំគ្នាមុខរដ្ឋបាលខណ្ឌចំការមន ក៏ប៉ុន្តែត្រូវអាជ្ញាធររារាំងមិនឱ្យជួបជុំ ដោយហេតុផលថា ពលរដ្ឋមិនបានភ្ជាប់មកនូវលិខិត ឬញត្តិជូនអាជ្ញាធរ។

លោក រ៉ាវី ឱ្យដឹងថា គោលបំណងដែលពលរដ្ឋជួបជុំគ្នានេះគឺដើម្បីទាមទារឱ្យអាជ្ញាធរផ្តល់ដីនៅតំបន់ចំពុះក្អែក សង្កាត់ព្រែកថ្មីជូនពួកគេ ជំនួសឱ្យផ្ទះដែលអាជ្ញាធរផ្តល់ជូននៅតំបន់ឈូករ៉ាវិញ ព្រមទាំងសំណងរុះរើផ្ទះ។ លោកថា ការដែលពលរដ្ឋទៅមុខរដ្ឋបាលខណ្ឌ ដោយសារអាជ្ញាធរបានដាក់ឱសានវាទឱ្យពួកគេរុះរើផ្ទះមុនថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។

លោកថា៖ «ពួកខ្ញុំអត់ចង់បានសំណងនោះទេ ព្រោះសំណងពួកខ្ញុំយកមករកកន្លែងរស់នៅអត់បាន។ ម្នាក់ៗកូនច្រើនពួកខ្ញុំស្នើសុំដោះដូរដីដូចនៅព្រែកប្រាដែលគាត់កាលពីឆ្នាំ ២០២៣ រាជរដ្ឋាភិបាលគាត់អភិវឌ្ឍន៍ប្រឡាយនៅខាងព្រែកប្រាហ្នឹង គេដោះដូរដីឱ្យទៅនៅក្រោយវត្តចំពុះក្រែកអ៊ីចឹងពួកខ្ញុំសុំដោះដូរទៅនៅហ្នឹងដែរទៅ ដើម្បីឱ្យមានដីសាងលំនៅស្ថានខ្លួនឯងវិញ»។

ពលរដ្ឋវ័យ៣៦រូបនេះឱ្យដឹងថា លោករស់នៅតំបន់បឹងត្របែកនេះតាំងពីឆ្នាំ២០១៧ ដែលផ្ទះលោកមានទទឹង៣ម៉ែត្រ បណ្តោយ១៦ម៉ែត្រ ហើយលោកទិញក្នុងតម្លៃ៦៥០០ដុល្លារអាមេរិកនៅកាលនោះ។ ក៏ប៉ុន្តែអន្តរក្រសួងវាយតម្លៃផ្ទះលោករួចឱ្យសំណងចំនួន២៥០០ដុល្លារ និងផ្ទះមួយខ្នងនៅតំបន់ឈូករ៉ា។

លោក លី រ៉ាវី ថាលោកមិនព្រមទទួលសំណងដែលអាជ្ញាធរផ្តល់ឱ្យគឺដោយសារផ្ទះដែលអាជ្ញាធរផ្តល់ឱ្យនៅឆ្ងាយពីក្រុង អាចលិចទឹកនៅខែវស្សា ហើយលោកទទួលដំណឹងថាផ្ទះនោះមានទំហំតូចគឺទទឹង៤ម៉ែត្រ និងបណ្តោយ៥ម៉ែត្រ។

អ្នករត់តាក់ស៊ី ដែលមានកូនក្នុងបន្ទុក ៣នាក់រូបនេះ ថាលោកមិនហ៊ានចេញទៅប្រកបរបរចិញ្ចឹមជីវិតនោះទេ ព្រោះបារម្ភអាជ្ញាធរចុះរុះរើផ្ទះលោកពេលលោកមិននៅផ្ទះ។ ករណីនេះ លោក រ៉ាវី អំពាវនាវឱ្យ រដ្ឋាភិបាលជួយអន្តរាគមន៍បញ្ហាពលរដ្ឋ។

លោកបន្ថែមថា៖ «សំណូមពរឱ្យរាជរដ្ឋាភិបាលមេត្តាជួយពួកខ្ញុំផង ពួកខ្ញុំសុទ្ធតែជនទីទ័លក្រទេ គ្មានលុយកាក់ឯណារកទីលំនៅសមរម្យនោះទេ។ ឱ្យតែរដ្ឋាភិបាលជួយពួកខ្ញុំ ឱ្យតែមានដីទៅពួកខ្ញុំសាងសង់ទីលំនៅស្ថានបានវិញមក ពួកខ្ញុំសប្បាយចិត្តហើយ ពួកខ្ញុំអត់តវ៉ារឹងទទឹងរឿងដែលគេអភិវឌ្ឍនទេ តាំងពីដើម»។

ចំណែកឯប្រជាសហគមន៍បឹងត្របែកភូមិ៥មួយរូបទៀតដែលបានទៅជួបជុំនៅមុខរដ្ឋបាលខណ្ឌចំការមនដែរនោះគឺអ្នកស្រី ឡួន សាវ៉េត វ័យ៣៨ឆ្នាំបានប្រាប់ថា គាត់រស់នៅតំបន់បឹងត្របែកនេះតាំងពីខ្ទង់ឆ្នាំ១៩៩៦មក ហើយបច្ចុប្បន្នសមាជិកគ្រួសារសរុបដែលនៅជាមួយគាត់មានចំនួន១៣នាក់។

អ្នកស្រីថា អាជ្ញាធរបានផ្តល់សំណងជាង៣ពាន់ដុល្លារអាមេរិក និងផ្ទះមួយខ្នងទទឹង ៤ម៉ែត្រ និងបណ្តោយ ៦ម៉ែត្រនៅតំបន់ឈូករ៉ា តែអ្នកស្រីមិនអាចទទួលយកបានទេព្រោះផ្ទះនោះទំហំតូចពេកសម្រាប់គ្រួសារគាត់។

អ្នកស្រីថា៖ «គេកំពុងតែបិទក្រដាសឱ្យរុះរើត្រឹមថ្ងៃ១០ ហើយខ្ញុំអត់ទាន់បានសំណងបានអីផង ខ្ញុំអត់ទាន់ទទួលបាន ហើយណាមួយខ្ញុំចង់ស្នើឱ្យខាងគាត់[អាជ្ញាធរ]ជួយឱ្យដូរពួកខ្ញុំបានទៅនៅខាងចំពុះក្អែកអ៊ីចឹង ខ្ញុំអត់ចង់ទៅនៅឈូករ៉ាទេ ពួកខ្ញុំទៅប៉ុន្មាននាក់ព្រឹកមិញហ្នឹងសុទ្ធតែចង់នៅជំពុះក្អែកទាំងអស់»។

អភិបាលខណ្ឌចំការមន លោក កៀងល័ក្ស ប្រាប់ថា អាជ្ញាធរបានរៀបចំផ្ទះជូនសហគមន៍បឹងត្របែករួចរាល់ហើយនៅតំបន់ឈូករ៉ា ខណ្ឌព្រែកព្នៅ ក៏ប៉ុន្តែនៅសល់ពលរដ្ឋជាង១០គ្រួសារទេដែលមិនព្រមទទួលសំណង។ ចំពោះសំណើដែលពលរដ្ឋទាមទារចង់បានដីនៅសង្កាត់ព្រែកថ្មី លោក កៀង ល័ក្ស ថាអាជ្ញាធរគ្មានគោលការណ៍ផ្តល់ជូនយ៉ាងនេះទេ។

លោកថា៖ «យើងអត់មានដីសម្រាប់ប្រជាសហគមន៍ វាអត់មានគោលការណ៍ហ្នឹង។ វាអត់មានគោលការណ៍ហ្នឹង។ អ្វីដែលយើងមាន យើងបានធ្វើផ្ទះបម្រុងទុកជូនពួកគាត់នៅភូមិអណ្តូង៦ និងអណ្តូង៤ នៅសង្កាត់គោករការ ខណ្ឌព្រែកព្នៅឯណោះ។ យើងបានរៀបចំផ្ទះសម្បែងអីជូនគាត់រួចរាល់អស់ហើយ»។

អភិបាលខណ្ឌចំការមនរូបនេះ ក៏បានព្រមានថា បើពលរដ្ឋមិនព្រមទទួលសំណង ហើយរុះរើផ្ទះទេនោះ អាជ្ញាធរនឹងចាត់វិធានការចុះរុះរើពេលផុតឱសានវាទនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦។

ជុំវិញករណីនេះ អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សុផាត ប្រាប់ប្រជាកាសែតថា ពលរដ្ឋដែលរស់នៅអមប្រឡាយលូនេះមានអ្នកព្រមចាកចេញ និងមានអ្នកចង់បានគឺការអភិវឌ្ឍន៍នៅហ្នឹងកន្លែងដដើម ក្រោយពីអាជ្ញាធរបានជូនដំណឹងឱ្យពួកគេចាកចេញជាច្រើនលើក។ ជាមួយគ្នានេះលោក ថាអាជ្ញាធរពិចារណាចំពោះអ្វីដែលពលរដ្ឋចង់បាន។

លោកថា៖ «អាជ្ញាធរគួរតែពិចារណាទៅលើសំណើរបស់ពួកគាត់ ពីព្រោះថាទោះបីយ៉ាងម៉េចក៏ដោយក៏ពួកគេជាប្រជាពលរដ្ឋខ្មែរ[...]សន្ធិសញ្ញាអន្តរជាតិមួយចំនួនដែលរាជរដ្ឋាភិបាលយើងបានផ្តល់សច្ចាប័ន ទាក់ទងនឹងសិទ្ធិមានដីធ្លី សិទ្ធិមានទៅលំនៅស្ថានសមរម្យនេះ គឺជាកត្តាអាទិភាពដែលរដ្ឋនីមួយៗគួរតែយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ»។

លោក វណ្ណ សុផាត ផ្តល់យោបល់ឱ្យអាជ្ញាធរពាក់ព័ន្ធរកដំណោះស្រាយណាដែលពលរដ្ឋទទួលយកបាន បើមិនដូច្នោះទេអាជ្ញាធរអាចប្រឈមការលំបាកក្នុងការដោះស្រាយបញ្ហាជាមួយពលរដ្ឋម្តងទៀតនៅពេលខាងមុខ។

លោកបន្ថែម៖ «នៅពេលណាដែលពួកគាត់មិនអាចរកចំណូលបាន មានទីលំនៅសមរម្យហ្នឹង គាត់ត្រូវរើចេញពីហ្នឹងម្តងទៀត។ រើចេញពីហ្នឹងម្តងទៀតទៅនៅកន្លែងណា? វិលចុះវិលឡើងអាចនៅកន្លែងណាដែលជា អាចឱ្យគាត់នៅបានតាមប្រឡាយតាមអីទៀតទៅ អាហ្នឹងធ្វើឱ្យអាជ្ញាធរហ្នឹងមានបញ្ហាម្តងទៀតក្នុងការដោះស្រាយ»។



8

1 share

Like Comment Share